# សិលាចារឹកទួលអង្គក្រសាំងផ្នារ K.១៤៣៩ (ភាគ១)

សិលាចារឹកនេះរកឃើញនៅក្នុងកំឡុងឆ្នាំ២០០៧ នៅពេលក្រុមឈ្មួញទិញអាចម៍ដីកាយយកអាចម៍ដីនៅទួលអង្គក្រសាំងផ្នារ ស្ថិតនៅក្នុងភូមិព្រៃកំពឹស សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ក្រុមអ្នកកាយដីនិងដឹកដីទាំងនោះ ពុំដឹងថាខ្លួនកាយបានវត្ថុបុរាណមួយចំនួននោះទេ។ លុះពេលដឹកដីនោះទៅដីចាក់បំពេញដីផ្ទះរបស់លោក អ៊ុយ សាខឿន ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិក្រាំងស្វាយ សង្កាត់ព្រែកកំពឹស ខណ្ឌដង្កោ រាជធានីភ្នំពេញ ទើបបានប្រទះឃើញនូវផ្ទាំងសិលាចារឹកនេះ ព្រមទាំងស្ពានទ្រទីផង។ លោក អ៊ុយ សាខឿន ក៏បានរក្សាទុកវត្ថុបុរាណទាំងពីរនេះរហូតមក ប៉ុន្តែការរក្សានេះត្រូវបានចល័តដាក់នៅទីតាំងផ្សេងៗគ្នា ព្រោះគាត់ត្រូវការកន្លែងសម្រាប់សាងសង់ផ្ទះថ្មី។ ពេលមួយសិលាចារឹកនេះ បានបែកបាក់ជាបីបំណាក់ ព្រោះត្រូវឡានដឹកដីកិនបាក់។

សិលាចារឹកនេះ ចារនៅលើថ្មស្រទាប់ ដែលមានកម្ពស់អតិបរមា៩៧ស.ម. ទទឹង ៤២ស.ម. និងកម្រាស់៨,៥០ស.ម.។ កម្ពស់អត្ថបទចារឹកជាមធ្យមមានប្រវែង៣៦ស.ម. ទទឹងចារឹកអត្ថបទជាមធ្យមមានប្រវែង៣៤ស.ម. និងមានគម្លាតចារអក្សរបន្ទាត់នីមួយៗជាមធ្យមមានប្រវែងចន្លោះពី២ស.ម. ទៅ៣ស.ម.។ ថ្មស្រទាប់បែបនេះ គេសង្កេតឃើញនិយមប្រើប្រាស់តែនៅសម័យមុនអង្គរ ប៉ុន្តែអត្ថបទចារឹកនេះមានចុះកាលបរិច្ឆេទនៅមហាសករាជឆ្នាំ១០៨៤ ត្រូវនឹងគ្រិស្តសករាជឆ្នាំ១១៦២ ស្ថិតនៅក្នុងរាជ្យព្រះបាទយសោវម៌្មទេវទី២ (១១៦០-១១៦៥ គ.ស.) ទៅវិញ។ ការណ៍នេះ ក៏ជួបប្រទះច្រើនកន្លងមកហើយ គឺសន្និកថ្មដែលជ្រើសរើសយកមកចារនោះ ជាសម្ភារៈសំណង់ដែលប្រើប្រាស់ក្នុងសំណង់ប្រាសាទសម័យមុនអង្គរ និងក្រោយមកនៅពេលប្រាសាទដើមនោះបាក់បែកខូចខាត ឬត្រូវរុះរើចោល គេក៏យកផ្នែកផ្សេងៗនៃសំណង់នោះមកប្រើតាមតម្រូវការ។ ដូច្នេះហើយ យើងអាចសន្និដ្ឋានបានថា នៅម្តុំទីរកឃើញសិលាចារឹកនោះ ប្រាកដជាមានបុរាណដ្ឋានកាលពីសម័យមុនអង្គរដាក់ជាពុំខាន និងមានមនុស្សរស់នៅគោរពបូជាបន្តសកម្មភាពទី

អត្ថបទដោយៈ ហ៊ុន ឈុនតេង

នោះរហូតមក យ៉ាងហោចណាស់ក៏ដល់ស.វ.ទី១៣ ដូចមានសិលាចារឹកនេះជាភស្តុតាងផងដែរ។ អ្វីដែលគួរបញ្ជាក់បន្ថែមនៅទីនេះ គឺនៅតំបន់ដែលរកឃើញសិលាចារឹកនេះ មានបុរាណដ្ឋានសម័យមុនអង្គរមួយចំនួនដែលយើងអាចស្គាល់បានដូចជា វត្តព្រះធាតុ[១] ទួលក្រាំងព្រះពុទ្ធ[២] វត្តប្រាសាទ និងវត្តជើងឯក[៣] ជាដើម។

សិលាចារឹកនេះបានបាក់ជាបីបំណាក់ នៅផ្នែកខាងស្តាំត្រង់បន្ទាត់ទី៧ដល់ទី១១ មានបាត់បំណែកមួយដុំដែលនាំឱ្យបាត់អក្សរមួយចំនួន ប៉ុន្តែនៅសល់អក្សរ៩៩ភាគរយដែលអាចអានបាន។ អត្ថបទមានចំនួន១២បន្ទាត់ ចារជាភាសាខ្មែរបុរាណ និងអក្សរខ្មែរបុរាណ នៅក្នុងគ្រិស្តសករាជឆ្នាំ១១៦២។ អក្សរដែលប្រើចារលើសិលាចារឹកនេះ មានទម្រង់ជាអក្សរមូលជ្រៀង ជាអក្សរដែលមិនប្រើជាផ្លូវការលើសិលាចារឹករបស់ព្រះរាជាឡើយ ឬអាចនិយាយបានថាជាទម្រង់អក្សររបស់អ្នកស្រុកប្រើប្រាស់។

អត្ថន័យនៃសិលាចារឹកនេះ គឺជាបញ្ជីតង្វាយខ្ញុំបម្រើព្រះ ឬពលព្រះចំនួន៧នាក់ និងដីស្រែទំហំពង្រោះ៧ថ្លង ២ជើ ៣លិះ ដែលគេថ្វាយចំពោះព្រះនៅទីនោះ។ តង្វាយទាំងនោះ គឺជាអំពើបុណ្យរបស់តេងដូនកញ្ញុំហោតា ព្រះគ្រូសុន្ទរមតីជាដើម។

## អត្ថបទអំណានអត្ថបទជាអក្សរខ្មែរទំនើប

១- ;.១០៨៤គកមងិយគក

២- ប្សរពោចមាគ្តិ(គិរ)កត្តិកលេយ អាទិត្យវារ

៣- គីនុយេងនាកញ្ញុំស្ពាបកវ្រះវុទ្ធរូបនរូប

---

[១] ទីតាំងនេះ ជាទីតាំងប្រាសាទដែលមានវត្តមានតាំងពីសម័យមុនអង្គរមកម្ល៉េះ និងបន្តកសាងបន្ថែមក្នុងរាជ្យព្រះបាទជ័យវម៌្មទេវទី៧។ បច្ចុប្បន្នប្រាសាទនេះ បានរលាយបាត់រូបរាងទៅហើយ នៅសល់តែសំណល់វត្ថុសិល្បៈមួយចំនួនទាំងសម័យមុនអង្គរនិងអង្គរ ដែលតម្កល់ទុកក្នុងបរិវេណវត្ត ក្បែរទីតាំងប្រាសាទចាស់។

[២] ទួលនេះ ជាអតីតប្រាសាទសម័យមុនអង្គរ និងជាទីរកឃើញសិលាចារឹកស.វ.ទី៧-៨មួយផ្ទាំង ចុះលេខសម្គាល់K.១៤១៣។ ទីតាំងនេះស្ថិតនៅខាងកើតវត្តព្រះធាតុ។ បច្ចុប្បន្នទីតាំងនេះត្រូវបានបំផ្លាញទាំងស្រុងទៅហើយ ដ្បិតបរិវេណនោះត្រូវបានអភិវឌ្ឍជាសំណង់បុរី។

[៣] នៅទីនោះ នៅសល់សំណល់វត្ថុសិល្បៈនិងសម្ភារៈសំណង់ប្រាសាទសម័យមុនអង្គរជាច្រើន ដែលរក្សាទុកនៅខាងជើងព្រះវិហារ។ ទីតាំងនេះ ជាទីតាំងរកឃើញសិលាចារឹក K.៤២៦ ផងដែរ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

៤- ព្រះអំតេងជេង្មៅតេង្ហនកញ្ញុំហោតាព្រះគុរុសុន្ទ

៥- រមតិតជាយ(ជ)មានព្រះគុរុសាសនបន្ទិត ខ្ញុំនុគ្រេ

៦- តជាជំ[ន្វនិ]ពោះតបាញ្ជីយនេះ តែកំវ្ងកក្វន

៧- តែកន្សុត តែកទ្រាតក្វនតែសុលក្ក តែកន្ទីរ

៨- គិកន្សំ គិកន្ទួន ផ្សំខ្ញុំប្រំវ្យល គ្រេបទិ[[គះ]]

៩- េ[្រ]គ {3} (ទក្ស្សិ)ណនោះព្រោះថ្វងី២ជេ២ គ្រេ៣ [[បគ្និ]]

១០- មត្រវាងវាយនៃបុតិព្រះព្រោះថ្វងី៣ គ្រេជេង {1?}

១១- ម្វេងបគ្និមព្រះគ្រេ២ អំព្យរព្រោះថ្វងី២ជេ១លិះ៣

១២- ផ្សំព្រោះថ្វងីប្រ[[ំ]]វ្យលិជេ២លិះ៣ ៙

## អត្ថបទប្រែសម្រួលជាភាសាខ្មែរទំនើប

មហាសករាជឆ្នាំ១០៨៤ (១១៦២ គ.ស.) ឆ្នាំមមី ពីរពោច ខែមិគសិរ ខែកត្តិក(នៅ?) ឡើយ ថ្ងៃអាទិត្យ គឺនូវយើងនៅកញ្ញុំអ្នកសាងព្រះពុទ្ធរូបនិងរូបព្រះអំតែងជេង្មៅ។ តេងជូនកញ្ញុំហោតា ព្រះគ្រូសុន្ទរមតី គឺជាយជមានព្រះគ្រូសាសនបណ្ឌិត។ ខ្ញុំបម្រើនិងស្រែដែលជាជំនូនតង្វាយមានដូចកត់ត្រាក្នុងបញ្ជីនេះ។ តែកំវ្ងក(និង)កូន(គឺ)តែកន្សុត តែកទ្រាត់(និង)កូន(គឺ)តែសុលក្ក តែកន្ទីរ សិកន្សំ សិកន្ទួន ផ្សំទាំងអស់ខ្ញុំបម្រើ៧នាក់។ ស្រែ--- ស្រែ---ខាងត្បូងនោះ ទំហំពង្រោះ២ថ្លង ២ជើ ៣ស្រែ ខាងបស្ចិមត្រពាំងពាយ ខាងនិរតីព្រះ(/ប្រាសាទ) ទំហំពង្រោះ៣ថ្លង ស្រែជើង-ម្វេង ខាងបស្ចិមព្រះ ២ស្រែ ទំហំពង្រោះ២ថ្លង ១ជើ ២លិះ។ ផ្សំទំហំពង្រោះទាំងអស់៧ថ្លង ២ជើ ៣លិះ៕

(នៅមានត)

អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



រូបសិលាចារឹកនិងស្អានទ្រនី ដែលទទួលបានពេលឡានចាក់ដី (រូបថត៖ ហ៊ុន ឈុនតេង, ២០១៦)



រូបសិលាចារឹកនិងស្អានទ្រនី ដែលទទួលបានពេលឡានចាក់ដី (រូបថត៖ ហ៊ុន ឈុនតេង, ២០១៦)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



រូបថតសិលាចារឹកទួលអង្គក្រសាំងធ្នារ (រូបថតៈ ហ៊ុន ឈុនតេង, ២០១៦)



រូបថតសិលាចារឹកទួលអង្គក្រសាំងធ្នារ (រូបថតៈ ហ៊ុន ឈុនតេង, ២០១៦)

អត្ថបទដោយៈ ហ៊ុន ឈុនតេង



*សំណៅសិលាចារឹកទួលអង្គក្រសាំងផ្ទារ (ហ៊ុន ឈុនតេង និង ឡា សុខហេង, ២០១៦)*

អត្ថបទដោយៈ ហ៊ុន ឈុនតេង